# ច្បាប់រាជនេតិ ឬ ច្បាប់ព្រះរាជសម្ភារ[១]

## បទកាកគតិ

ហែសាធុជនផង នេះគឺចំណាង បទបាលីថា
គម្ពីរសធម៌ អាណាក្រិត្តិកា គួរគប្បីមហា-
ជនផងត្រងត្រាប់ ។

ធម៌នេះដំបូន្មាន រួមរក្សាប្រាណ ឱ្យបានក្ដីគាប់
ដ៏លោកបរលោក ហៅរស់ពុំស្លាប់ ធម៌នេះជាច្បាប់
ក្ដីគាប់បរិយាយ ។

កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្ក្រម៍ កុំទុកចិត្តអភិប្រាយ
ប្រើទំលែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្ដាប់ពាក្យបរិយាយ
បណ្ឌិបមេធី ។

កុំដើយដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី
កុំកាន់ពិសយង់ គប់នឹងស្ដ្រី សមណៈជនជី
កុំឱ្យក្ដីត្រូវ ។

កុំនៅញាំងឈ្លោះ កុំស្ដាប់អសុរស កុំស្ដាប់អាស្រូវ
កុំដើរពានស្គុន កុំស្កាត់ច្រកផ្លូវ កុំធ្វើស្រែស្រូវ
លើផ្លូវដំរី ។

ផ្អែមពីរប្រការ ចំណីនៅដាល កុំអាលអោយឆី
ផ្អែមមួយពាក្យពាល វែងរាលរកក្ដី ផ្អែមមួយពាក្យស្រី
ស្រដីមាយា ។

ពាក្យត្រូវវែងរឹង ស្រាវែងស្រវឹង ពុំដែលពិសា
ពាក្យពិតវែងស្លែង ពុំពិរោះថា បណ្ឌិបមេបា
វែងថាពុំគាប់ ។

ខ្លៅវែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រច័ណ្ឌ វែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់
វែងស្អប់ប្រដៅ ។

ចង់បុណ្យបានបាប ចចើងចង់លាភ វែងបាត់ធនទៅ
មានះមាត់មិត្រ ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅ
រមែងបាត់អង្គ ។

---

[១] តាមការផ្សាយរបស់សមាគមសម្ដេច ជួន ណាត (ឆ្នាំ១៩៧៤)

ស្វែងគាប់បានយស ចង់ស្វែងរបស់ ប្រើចេះផ្គាប់ផ្គង់
ចង់ធំកុំអួត ដើមមានពូជពង្ស ចង់ឱ្យខ្លួនត្រង់
ប្រើផ្គាប់អ្នកមុខ ។

ខ្លែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាអោយសុខ
ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក
ដ្បិតភរិយាផា ។

បាត់យសដ្បិតខ្ជិល បាត់ញាណទានសីល ដ្បិតសេពសុរា
ប្រមាថបាត់បុណ្យ ខឹងបាត់ប្រាជ្ញា លេញលេងដៀលថា
បាត់ឥរិយាគាប់ ។

អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ
មេត្រីជាញាតិ រក្សាដល់ស្លាប់ ចៀសក្តីពុំគាប់
ជាគន្ធពិដោរ ។

ទឹកបាក់ទៅទាប បុណ្យបាត់ដ្បិតបាប លាភបាត់ដ្បិតឃោរ
ទឹកថ្លាដ្បិតរលក ពុំយល់ស្រមោល ទោសកើតដ្បិតពោល
ល្មមមាត់ឈ្លានពាន ។

ខ្លៅរែងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច រែងធ្វើជាហាន
ខ្សត់ខ្សោយស្អុតទ្រុឌ រែងធ្វើជាមាន អ្នកឥតសន្តាន
រែងគេមើលងាយ ។

ទាហានថ្កើងដ្បិតសឹក ធ្វើស្រែដ្បិតទឹក ត្រឹកពលដ្បិតបាយ
សិស្សប្រាជ្ញដ្បិតគ្រូ ដេរពោលជំវាយ ពលជាដ្បិតនាយ
ហ្វឹកហ្វឺនខះខំ ។

រៀនក្តីគួរគិត ចាស់ឥតប្រព្រឹត្តិ នៅប្រែប្រឡំ
អ្នកជាជាកាច តូចប្រែជាធំ ពូជពង្សឧត្តម
ប្រឡំជារាស្ត្រ ។

ឃើញសេះជាលា ក្ងានជាទា ពពាយជាទាស
សំណជាប្រាក់ ស្ពាន់ឆ្លាក់ជាមាស បង្គួយជាផាស
កប្បាសជាគ ។

ហេតុនេះគួរគិត គួររិះរកហិត ដឹងរសគន្ធរ
ពិដោរអសុដោរ ពិសាសាទរ ហិតហើយសឹមប–
រិភោគ្គាក្លិត ។

ល្ពឹកឮពាក្យពេចន៍ សាកសួររកសាច់ សន្តានព្រេងព្រឹទ្ធ
រកវិះកលអ្វី សុចរិតទុច្ចរិត ហើយហោងគួរគិត
ឱ្យដឹងខ្ពស់ទាប ។

ដូចខ្វាក់បាំងស្បែក មួយដូចទំពែក ចង់សុំប្រេងលាប
ដូចថ្លង់ស្តាប់ច្រៀង ទះដៃព្រាបៗ ដូចខ្វិនអាបឡាប
ចង់ចងក្បិនរត់ ។

ពុតព្នាយមានបី មួយដូចដំរី សាហាវឥតបទ
អាចផ្សះផ្សាំងបាន កង្វេរកាន់កត់ ដាលដេញគោតគត់
ប្រាំមួយហត្ថហោង ។

មួយចង់ឈ្នានីស ចិត្តចង់ចចេស ពុំដោយគន្លង
ពាក្យពោលអ្នកធំ ច្រឡំសួរសង ពុំគិតក្តីហ្មង
ចង់ចេរអន្តរាយ ។

មួយស្រីពេស្យា បំពេញព្រហ្មចា– រីយ៍រួសអភិប្រាយ
អំពើទាំងបី ហៅពិសពុតព្នាយ សាធុសម្ងាយ
ចៀសកុំបីត្រាប់ ។

ប្រាជ្ញពុំស្មើពុត បំរើលំអុត ពុំស្មើក្តីគាប់
មានគុណពុំស្មើ អ្នកមានបុណ្យភ័ព្វ ស្វែងរករៀនច្បាប់
ពុំស្មើចិត្តជា ។

ស័ក្តិពុំស្មើយស អ្នកមានរបស់ ពុំស្មើស័ក្តា
សូវបង់ធនធាន កុំខុសអាជ្ញា សូវមានរោគា
កុំអោយមើលងាយ ។

សូវសុំកុំយក គ្នាស្មើកុំរក ដូចបាវនិងនាយ
ខុសគាប់សូវអត់ កុំឱ្យឮឆ្ងាយ ក្តីសុខមទាំងឡាយ
កុំខ្វាយសួរស័ព្ទ ។

ធម៌នេះដំបូន្មាន រួមរក្សាប្រាណ អោយមានក្តីគាប់
សូវបង់ធនធាន កុំអោយខ្លួនស្លាប់ សូវស្លាប់ទៅគាប់
រសេធម៌កុំបង់ ។

បណ្តាំមេបា អំបូរលោកថា ទុកតាមកំពង់
សំពៅតាមខ្យល់ ចង្កូតតម្រង់ មេលឹមតែងត្រង់
ត្រីវិស័យជាមុខ ។

ដូចប្ដីចិត្តជា ដូចមានភរិយា នៅផ្ទះស្រណុក
ដូចកូនទទួល យកពាក្យអោពុក ដូចខ្ញុំអោយមុខ
អម្ចាស់ប្រើហៅ ។

បណ្ដាំមេបា អំបូរលោកថា ព្រេងព្រឹទ្ធប្រដៅ
ទើងឆីប្រើរក ទើងស្វែងប្រើទៅ ទើងស្នេហ៍ប្រើហៅ
មិត្រមកជាមិត្រ ។

ពាក្យខុសកុំស្ដាប់ ក្ដីខុសកុំត្រាប់ អ្នកកាចកុំផ្គិត
ល្ងង់កុំស្រដី ខ្សត់កុំទុកចិត្ត ពាលោកុំផ្គិត
ជាមិត្រមេត្រី ។

ប្រើថ្លឹងអោយស្មើ ទោះបីនឹងប្រើ ប្រើអ្នកចេះក្ដី
កុំយកពាក្យស្លោក ផ្ទឹមនឹងគម្ពីរ កុំយកពាក្យជី
ផ្ទឹមនូវពាក្យពាល ។

មើលភ្នែកជញ្ជឹង ក្នុងចិត្តអោយដឹង ណាធ្ងន់ណាស្រាល
កុំយកមណីរ័តន៍ មាសមានជាកាល ចិត្តកុំបណ្ដាល
នូវបង់សីលធម៌ ។

ប្រើដឹងតុលហាប ប្រើដឹងខ្ពស់ទាប មានភ្នែកយល់ល្អ
ទោះដឹងទឹកមាស ពុំចេះនូវថ្ម ទោះដឹងដីស
ពុំចេះសំបុត្រ ។

ធ្វើស្រែមើលស្មៅ សន្តានមើលផៅ បំរើមើលពុត
ទោះដឹងពុតជា ពុំចេះពុតត្បុត ដឹងចិត្តបរិសុទ្ធ
ពុំចេះឥរិយា ។

ទេពីមើលក្រិត្យ ក្សត្រាមើលឫទ្ធិ ទាហានមើលចេស្ដា
ជាងមើលអំពើ អំពីហត្ថា ទោះយកភរិយា
មើលនាលំនៅ ។

អសារក្ដារបី បណ្ដាំមេជី ព្រេងព្រឹទ្ធប្រដៅ
អង្គរសសុទ្ធ ចម្អិនអោយឆៅ ពិសីហើយខ្លៅ
ប្រាជ្ញឥតមារយាទ ។

អ្នកបួសឥតក្រឹត្យ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាថ
ភរិយាផុយផាយ ចាយវាយឥតខ្នាត ពពាលសុទ្ធសាធ
ប្រដៅក្របាន ។

## ព្រះរាជសម្ភារ (១៦០៤ —១៦៣៤ គស.)

ផ្ទះភ្លើងមានបី អំពើពុធស្រី ខឹងឥតប្រមាណ
កូនកាចចចេស ពុំដោយដំបូន្មាន ខ្ញុំកាចកៀសប្រាណ
ពុំអោយម្ចាស់ប្រើ ។

ហោរាប្រើគួរ ភមូប្រើមូល ស្នង់ទឹកប្រើស្មើ
បន្ទាត់ប្រើត្រង់ ពលផ្ទង់គប្បីប្រើ ពុំហើយគប្បីធ្វើ
កុំលេងគប្បីភ្វា ។

ក្តីកោតមានបី កោតមួយពួកស្រី ស្រដីមាយា
កោតមួយពាក្យពិស អាស្រូវជេរថា កោតមួយពាក្យពា–
លោលោកទុជ៏ន ។

ពិសពស់នានា កុយខ្នាយទន្តា កាលគត់ស្តាប់មន្ត
ត្រង់ពិសពាក្យពាល រោលរាលពុំស្រន់ សូម្បីអស់ជន្ម
ក្រមន្តប្រោសបាន ។

ហេតុនេះគួរគិត គួររិះរកហិត ថ្នាំពិសអោយស្រាន្ត
ដ៏លោកនេះគួរ រកអ្នកទ្រង់ញាណ សេពសាងសីលទាន
ជាថ្នាំលោកិយ ។

រីថ្នាំបរលោក ចៀសចាកទុក្ខសោក បង់បញ្ចិន្ទ្រិយ
គប្បីផឹកសត្តតិង្ស ពោធិបក្ខិយ អាចនាំដល់ត្រី–
ពិធសម្បត្តិសារ ។

ពិដោរផ្កាបី ពិដោរមេត្រី សួស្តីសីលាចារ
ពិដោរបរិសុទ្ធ កុសលសម្ភារ ពិដោរនេះដាល
ដល់សួគ៏ពុំស្បើយ ។

ពិដោរផ្កាបី ក្រៃលែងក្លិនភ្វី ឥតឯល្ហែល្ហើយ
ដោយខ្យល់ច្រាសខ្យល់ នៅត្រើយឆ្លងត្រើយ ពិដោរពុំស្បើយ
ហៅរសគន្ធា ។

ពិសាផ្លែប្រាំ ពិសារសធម្ម ពិសាសត្យា
ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសារសវា–
ចាចេញមធុរ ។

ពិសាផ្លែប្រាំ  គិតជានាយនាំ  ឥន្ទ្រិយទៅចូល
ត្រីពិធសម្បត្តិ  ទិព្វរ័តន៍អនុកូល  ចំណោទៅចូល
មោក្ខមគ្គាល័យ ។

ធម៌នេះជាច្បាប់  ប្រសើរមហាគាប់  ឧត្តមពេកក្រៃ
ក្រអ្នកណាបាន  ប្រាជ្ញាឈ្លាសវៃ  អាចដឹងដោយន័យ
រសធម៌គាថា ។

គួរចេះគួរចាំ  គួរតាមបណ្តាំ  ទូលទុកសិរសា
ធម៌នេះស្មើក្សីរ  អម្រឹតធារា  សម្តេចភគវា
សាធុប្រោសប្រាណ ។

អ្នកណាបានស្តាប់  អ្នកណាបានត្រាប់  អ្នកណាបានធ្យាន
រសធម៌នេះគាប់  ជាច្បាប់ទូន្មាន  អ្នកនោះស្មើបាន
ដល់និព្វានហោង ។